ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..០៣...សសរ

## សេចក្តីសម្រេច

## ស្តីពី

## សេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ/បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ .-**

ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ, ពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងគូអង្គអភិវឌ្ឍន៍ ។

**ប្រការ ២ .-**

ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការសម្របសម្រួល, ពិគ្រោះយោបល់ និងគាំទ្រដល់ការអនុវត្តផែនការ និងយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ដើម្បីឈានទៅអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ ។

**ប្រការ ៣ .-**

ក្រុមការងារបច្ចេកទេសចម្រុះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានក្រសួង ឬស្ថាប័ន ។ ប្រធានក្រសួង ឬស្ថាប័ន ត្រូវមានគណនេយ្យភាពចំពោះមុខរាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបានលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។

**ប្រការ ៤ .-**

ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវប្រើប្រាស់សេចក្តីណែនាំនេះ ដើម្បីពង្រឹងការងាររបស់ខ្លួន តាមរយៈការរៀបចំលក្ខខ័ណ្ឌយោង និងការកំណត់របៀបរបបធ្វើការដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់ក្រុមការងារខ្លួន ក៏ដូចជាការរៀបចំកម្មវិធីការងារដែលឆ្លើយតបនឹងអាទិភាពការងារបច្ចុប្បន្ន ដោយត្រូវពិភាក្សាជាមួយនឹងសមាជិកនៃក្រុមការងារ និងប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ។

**ប្រការ ៥ .-**

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្តល់ការគាំទ្របច្ចេកទេស តាមសំណើរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ។

**ប្រការ ៦ .-**

ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ, ប្រធាន និងសមាជិកក្រុមការងារបច្ចេកទេសចម្រុះ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ